00785023

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préliminaire

លេខ/No: D11/1/4/2

*តាមនាមប្រជារាស្ត្រខ្មែរ និងតាមនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពី ការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ*

**សំណុំរឿងព្រហ្មទណ្ឌលេខ:** ០០៣/០៧-០៩-២០០៩-អវតក/កសចស (អបជ ០១)

**ចំពោះមុខ:**
ចៅក្រម ប្រាក់ គឹមសាន ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម នី ថុល
ចៅក្រម Katinka LAHUIS
ចៅក្រម ហួត វុទ្ធី

**កាលបរិច្ឆេទ:** ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ២០១២

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 28 / 02 / 2012
ម៉ោង (Time/Heure): 15:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: Ratanak

**សាធារណៈ (សំណៅកោសលុប)**

**សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ ទាក់ទិននឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេច ស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ [redacted]**

**សហព្រះរាជអាជ្ញា**

ជា លាង
Andrew CAYLEY

**មេធាវីតំណាងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី**

ជួង ជូងី

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C

00785024



**អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") បានទទួល "បណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាសម្រេចស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ [redacted] ដែលបានដាក់ដោយ [redacted] ("ម្ចាស់បណ្តឹងឧទ្ធរណ៍") នៅថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១១ ("បណ្តឹងឧទ្ធរណ៍")[១]។

## I. ប្រវត្តិនីតិវិធី និង សារណានានា

១. នៅថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩ អតីតសហព្រះរាជអាជ្ញាអន្តរជាតិស្តីទី បានដាក់ "ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទី២ [redacted][២] ("ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទី២") ជូនទៅសហចៅក្រមស៊ើបអង្កេត ដោយស្នើសុំសហចៅក្រមស៊ើបអង្កេតឲ្យបើកកិច្ចស៊ើបសួរលើសំណុំរឿង ០០៣។ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទី២ ត្រូវបានដាក់ជាឯកសារសម្ងាត់ ហេតុដូច្នេះហើយសាធារណៈជន ជនរងគ្រោះ និងអ្នកដែលនឹងក្លាយជាដើមបណ្តឹងរដ្ឋប្បវេណី រួមទាំងម្ចាស់បណ្តឹងឧទ្ធរណ៍ ពុំមានសិទ្ធិពិនិត្យមើលដីកានេះឡើយ[៣]។

២. នៅថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០១១[៤] តាមរយៈលទ្ធផលដែលបានស្រាវជ្រាវលើព័ត៌មាន ដែលមានជាសាធារណៈ[៥] ម្ចាស់បណ្តឹងឧទ្ធរណ៍ បានដាក់ពាក្យសុំជាសាធារណៈមួយ ជូនទៅអង្គភាពគាំពារជនរងគ្រោះនៃ អ.វ.ត.ក ("អង្គភាពគាំពារជនរងគ្រោះ") ក្នុងគោលបំណងស្នើសុំឲ្យទទួលស្គាល់ខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០៣ និង សំណុំរឿង ០០៤ នៅចំពោះមុខ អ.វ.ត.ក ("ពាក្យសុំ")[៦]។ ម្ចាស់បណ្តឹងឧទ្ធរណ៍បានអះអាងនៅក្នុងពាក្យសុំរបស់ខ្លួនថា ខ្លួនបាន

---

[១] បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេច ស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ [redacted] ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១១ ឯកសារលេខ D11/1/4/1 ("បណ្តឹងឧទ្ធរណ៍")។

[២] សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី នៃការដាក់ឯកសារស្តីពីដីកាសន្និដ្ឋានបញ្ជូនរឿងស៊ើបសួរទី២ ចុះថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩ ឯកសារលេខ D1/1។

[៣] ទោះបីជាយ៉ាងនេះក្តី នៅថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២០០៩ សហព្រះរាជអាជ្ញាអន្តរជាតិស្តីទីបានបញ្ជាក់ជាសាធារណៈតាមរយៈសេចក្តីប្រកាសព័ត៌មានមួយថា ខ្លួនបានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទី២ (សេចក្តីប្រកាសព័ត៌មាន៖ សេចក្តីប្រកាសរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី ចុះថ្ងៃទី 8 ខែ កញ្ញា ឆ្នាំ ២០០៩)។

[៤] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ១។

[៥] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៨ និងកថាខណ្ឌ ២២។

[៦] ទម្រង់បែបបទស្តីពីព័ត៌មានជនរងគ្រោះ ចុះថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០១១ ឯកសារលេខ D11/1 ("ពាក្យសុំ") ទំព័រទី ៥។

ទទួលរងនូវការខូចខាត ដោយសារផលវិបាកដោយផ្ទាល់នៃឧក្រិដ្ឋកម្មដែលស្ថិតនៅក្រោមយុត្តាធិការរបស់ អ.វ.ត.ក ដែល [redacted] បានប្រព្រឹត្តមកលើខ្លួន និងគ្រួសាររបស់ខ្លួន។ ជាពិសេស ម្ចាស់បណ្តឹងឧទ្ធរណ៍បានប្រកាសថា ការខូចខាតរបស់ខ្លួន ជាប់ពាក់ព័ន្ធនឹងការជួលរលំ និងការជម្លៀសទីក្រុងភ្នំពេញ រួមទាំងការផ្លាស់ទីលំនៅប្រជាជនពីភូមិភាគបូព៌ាផងដែរ ដែលក្នុងអំឡុងពេលនោះ ខ្លួនត្រូវបានទទួលរងការជម្លៀសដោយបង្ខំ ការចាប់ខ្លួន និងឃុំខ្លួនដោយខុសច្បាប់នៅមន្ទីរសន្តិសុខវត្តធ្លក និងមន្ទីរសន្តិសុខបឹងរ៉ៃ ការងារដោយបង្ខំលើកុមារ ការធ្វើទារុណកម្ម និងការធ្វើបាបយ៉ាងសាហាវ និងអមនុស្សធម៌ *ក្នុងចំណោមបណ្តាអំពើផ្សេងទៀត*[៧]។ ម្ចាស់បណ្តឹងឧទ្ធរណ៍ក៏បានលើកឡើងផងដែរថា ខ្លួនបានទទួលរងការខូចខាតដោយផ្ទាល់ពីការបាត់បង់ឪពុកម្តាយរបស់ខ្លួន ដែលជាជនរងគ្រោះនៃការបាត់ខ្លួនដោយបង្ខំ និងការកាប់សម្លាប់ដោយខ្មែរក្រហម។ ពាក្យសុំនេះត្រូវបានអង្គភាពគាំពារជនរងគ្រោះដាក់ជូនសហចៅក្រមស៊ើបអង្កេត នៅថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០១១[៨]។

៣. នៅថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១ ជាថ្ងៃតែមួយដែលសហចៅក្រមស៊ើបអង្កេត បានចេញសេចក្តីជូនដំណឹងអំពីការបញ្ចប់ការស៊ើបសួររបស់ខ្លួននៅក្នុងសំណុំរឿង ០០៣[៩] សហចៅក្រមស៊ើបអង្កេតបានចេញ "ដីកាសម្រេចស្តីពីការទទួលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ [redacted]"[១០] ("ដីកាសម្រេចដែលត្រូវបានជំទាស់") ដោយបានប្រកាសមិនទទួលយកពាក្យសុំរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ ដែលបានស្នើសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០៣។ សហចៅក្រមស៊ើបអង្កេតបានរកឃើញថា ពាក្យសុំរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ពុំអាចទទួលយកបាន ដោយហេតុថា ការខូចខាតដែលម្ចាស់បណ្តឹងឧទ្ធរណ៍បានទទួលរង "មិនមានការពាក់ព័ន្ធ

---

[៧] ពាក្យសុំ ទំព័រទី ៣ និងទំព័រទី ៤ និងឯកសារភ្ជាប់ជាមួយនឹងពាក្យសុំ ទំព័រទី ១-៨។ បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ១៣។

[៨] ពាក្យសុំ ទំព័រទី ១។

[៩] សេចក្តីជូនដំណឹងអំពីការបញ្ចប់ការស៊ើបសួរ ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១ ឯកសារលេខ D13។ សេចក្តីប្រកាសព័ត៌មាន៖ សេចក្តីប្រកាសរបស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១។

[១០] ដីកាសម្រេចស្តីពីការទទួលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ [redacted] ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១ ឯកសារលេខ D11/1/3 ("ដីកាសម្រេចដែលត្រូវបានជំទាស់")។

ជាមួយនឹងអង្គហេតុ ដែលស្ថិតនៅក្រោមការស៊ើបសួរឡើយ”[១១]។ សហចៅក្រមស៊ើបអង្កេតបានផ្តល់សំអាងហេតុថា ស្ថានភាពអង្គហេតុ នៃព្យសនកម្មដែលម្ចាស់បណ្តឹងឧទ្ធរណ៍បានចោទប្រកាន់ថា បានកើតឡើងលើរូបខ្លួននោះ “[ពុំ] ជាប់ពាក់ព័ន្ធទៅនឹងអង្គហេតុ ដែលមានលើកឡើងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីពីរ [...] នោះទេ។ ហើយស្ថានភាពនៃអង្គហេតុទាំងនោះក៏មិនជាប់ទាក់ទងនឹងកាលៈទេសៈផ្សេងៗជុំវិញអង្គហេតុ ដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា ឬ ទំនងជាអាចមានប្រយោជន៍ដល់ការកំណត់អំពីធាតុផ្សំយុត្តាធិការ និងអំពីទម្រង់នៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជនសង្ស័យនោះដែរ”[១២]។ សហចៅក្រមស៊ើបអង្កេតបានលើកឡើងបន្ថែមទៀតថា ការចោទប្រកាន់ថាឧក្រិដ្ឋកម្មទាំងឡាយបានប្រព្រឹត្តឡើងដោយ [redacted] “មិនមានមូលដ្ឋានត្រឹមត្រូវតាមច្បាប់នោះទេ ដោយហេតុថា ឈ្មោះរបស់ជនសង្ស័យនៅក្នុងសំណុំរឿង ០០៣ មានលក្ខណៈសម្ងាត់ ហើយដូច្នេះឈ្មោះដែលមានលើកឡើងនៅក្នុងពាក្យសុំគឺមានលក្ខណៈជាការស្មានទុកប៉ុណ្ណោះ”[១៣]។

៤. នៅថ្ងៃទី ៩ ខែ ឧសភា ឆ្នាំ ២០១១ សហព្រះរាជអាជ្ញាអន្តរជាតិ បានចេញសេចក្តីប្រកាសជាសាធារណៈមួយ ដោយលាតត្រដាងនូវព័ត៌មានចេញពីដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទី២ ក្នុងនោះរួមមានឧក្រិដ្ឋកម្ម ដែលបានចោទប្រកាន់ និងទីតាំងឧក្រិដ្ឋកម្មដែលត្រូវបានស៊ើបអង្កេត[១៤]។

៥. នៅថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១១ ម្ចាស់បណ្តឹងឧទ្ធរណ៍បានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍[១៥] ជូនទៅសហចៅក្រមស៊ើបអង្កេត ក្នុងពេលដំណាលគ្នាជាមួយនឹងសារណាលើបណ្តឹង

---

[១១] ដីកាសម្រេចដែលត្រូវបានជំទាស់ កថាខណ្ឌ ១៤។

[១២] ដីកាសម្រេចដែលត្រូវបានជំទាស់ កថាខណ្ឌ ១២។

[១៣] ដីកាសម្រេចដែលត្រូវបានជំទាស់ កថាខណ្ឌ ១៣។

[១៤] សេចក្តីប្រកាសព័ត៌មាន៖ សេចក្តីប្រកាសរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីពីសំណុំរឿង ០០៣ ចុះថ្ងៃទី ៩ ខែ ឧសភា ឆ្នាំ ២០១១ (“សេចក្តីប្រកាសរបស់របស់សហព្រះរាជអាជ្ញាអន្តរជាតិ”)។ នៅថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១១ សហព្រះរាជអាជ្ញាអន្តរជាតិបានកោសលុបនូវសេចក្តីប្រកាសរបស់ខ្លួនវិញ ដើម្បីឱ្យស្របតាមសេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត លើសេចក្តីប្រកាសព័ត៌មានជាសាធារណៈរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទាក់ទងនឹងសំណុំរឿង ០០៣ (ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១១ ឯកសារលេខ D14/1/3) និងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតស្តីពីសេចក្តីប្រកាសព័ត៌មានជាសាធារណៈរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទាក់ទងនឹងសំណុំរឿង ០០៣ (ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១១ ឯកសារលេខ D14)។

ឧទ្ធរណ៍ជូនទៅអង្គបុរេជំនុំជម្រះ ស្របតាមវិធាន ៧៥ នៃវិធានផ្ទៃក្នុង។ បណ្ដឹងឧទ្ធរណ៍នេះបានដាក់ប្ដឹងអនុលោមតាមវិធាន ៧៤(៤)(ខ) និងវិធាន ៧៧ *ស្ទួន* នៃវិធានផ្ទៃក្នុង[១៦] ដោយបានលើកឡើងករណីពាក់ព័ន្ធនឹងសំណុំរឿង ០០៣ និង សំណុំរឿង ០០៤ នៅចំពោះមុខ អ.វ.ត.ក។ ការអះអាងរបស់ម្ចាស់បណ្ដឹងឧទ្ធរណ៍ ដែលពាក់ព័ន្ធនឹងរឿងក្ដីនេះ មានដូចតទៅ៖ ម្ចាស់បណ្ដឹងឧទ្ធរណ៍បានស្នើសុំឱ្យអង្គបុរេជំនុំជម្រះ i) ប្រកាសទទួលយកបណ្ដឹងឧទ្ធរណ៍ ii) ច្រានចោលដីកាសម្រេចដែលត្រូវបានជំទាស់ ដែលបានសម្រេចមិនទទួលយកខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០៣ និង iii) ផ្ដល់ឋានៈជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០៣ ជូនខ្លួនវិញ[១៧]។ មូលដ្ឋានទី៤ នៃបណ្ដឹងឧទ្ធរណ៍ ដែលគាំទ្រលើការអះអាងទាំងនេះ អាចធ្វើការសង្ខេបដូចតទៅនេះ៖ i) ម្ចាស់បណ្ដឹងឧទ្ធរណ៍មិនទទួលបានគោលការណ៍ជាសារវ័ន្តនៃភាពយុត្តិធម៌ផ្នែកនីតិវិធី ក្នុងការទទួលបានព័ត៌មានស្ដីពីវិសាលភាពនៃកិច្ចស៊ើបសួរលើសំណុំរឿង ០០៣ ឱ្យបានគ្រប់គ្រាន់ និងទាន់ពេលវេលា[១៨] ii) សហចៅក្រមស៊ើបអង្កេតខកខានមិនបានចុះស៊ើបអង្កេតដល់ទីតាំងឧក្រិដ្ឋកម្មទាំងអស់ និងហេតុការណ៍ល្មើសក្នុងសំណុំរឿង ០០៣ ជាពិសេស ដោយសារការស៊ើបអង្កេតដូច្នេះ វានឹងពាក់ព័ន្ធនឹងម្ចាស់បណ្ដឹងឧទ្ធរណ៍[១៩] iii) សហចៅក្រមស៊ើបអង្កេតបានអនុវត្ត និងបកស្រាយដោយភាន់ច្រឡំលើអង្គហេតុ និងអង្គច្បាប់ដែលពាក់ព័ន្ធនឹងទ្រឹស្ដីនៃសហឧក្រិដ្ឋកម្មរួមព្រមទាំងគោលបំណង និងគម្រោងរួម[២០] និង iv) សហចៅក្រមស៊ើបអង្កេតខកខានមិនបានចេញសេចក្ដីសម្រេច ដែលមានសំអាងហេតុចំពោះការមិនទទួលស្គាល់ម្ចាស់បណ្ដឹងឧទ្ធរណ៍ជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០៣[២១]។

៦. ពុំមានចម្លើយតបណាមួយត្រូវបានដាក់ចំពោះបណ្ដឹងឧទ្ធរណ៍នេះទេ។

---

[១៥] សេចក្ដីជូនដំណឹងអំពីបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១១ ឯកសារលេខ D11/1/4។

[១៦] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ១៨ និងកថាខណ្ឌ ៦០។

[១៧] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ៦៩។

[១៨] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ៧ និងកថាខណ្ឌ ២១-៣៣។

[១៩] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ៧ និងកថាខណ្ឌ ៣៤-៤៩។

[២០] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ៧ និងកថាខណ្ឌ ៥០-៥៤។

[២១] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ៧ និងកថាខណ្ឌ ៥៥-៦៦។

PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C. C.E.T.C.

៧. នៅថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០១១ ម្ចាស់បណ្តឹងឧទ្ធរណ៍បានផ្ញើឯកសារមួយដោយផ្ទាល់ជូនប្រធានអង្គបុរេជំនុំជម្រះ។ ក្នុងឯកសារនោះ គាត់បានសំដែងឆន្ទៈ “ដកខ្លួនចេញពីការចូលរួមតាមផ្លូវច្បាប់ទាំងអស់នៅ អ.វ.ត.ក” (“ឯកសារ”)។ នៅថ្ងៃជាមួយគ្នានោះ ក្រឡាបញ្ជីរបស់អង្គបុរេជំនុំជម្រះបានជូនដំណឹងដល់ម្ចាស់បណ្តឹងឧទ្ធរណ៍ថា ឯកសារនោះមិនអាចត្រូវចាត់ទុកជាឯកសារជាផ្លូវការដើម្បីដកបណ្តឹងឧទ្ធរណ៍របស់គាត់ឡើយ ហើយថា បើសិនជាគាត់មានបំណងបោះបង់ចោលបណ្តឹងឧទ្ធរណ៍នេះជាផ្លូវការ គាត់ត្រូវអនុវត្តតាមកិច្ចដំណើរការនីតិវិធីជាផ្លូវការក្នុងការជូនដំណឹងដល់អង្គបុរេជំនុំជម្រះ តាមរយៈក្រឡាបញ្ជីរបស់អង្គបុរេជំនុំជម្រះ ឱ្យបានច្បាស់លាស់ និងជាក់លាក់ អំពីឆន្ទៈច្បាស់លាស់ និងដោយស្ម័គ្រចិត្តក្នុងការបោះបង់ចោលបណ្តឹងឧទ្ធរណ៍របស់គាត់ ដោយអនុលោមតាមសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅ អ.វ.ត.ក (“សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ”)។ សេចក្តីជូនដំណឹងដដែលនោះ ត្រូវបានបញ្ជូនម្តងទៀតទៅកាន់ម្ចាស់បណ្តឹងឧទ្ធរណ៍នៅថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១១ បន្ទាប់ពីម្ចាស់បណ្តឹងឧទ្ធរណ៍ បានបញ្ជូនឯកសារនោះជាថ្មីម្តងទៀតទៅកាន់ប្រធានអង្គបុរេជំនុំជម្រះ។ មកដល់ពេលនេះ សេចក្តីជូនដំណឹងរបស់ក្រឡាបញ្ជីត្រូវបានបញ្ជូនតាមរយៈអាសយដ្ឋានសារអេឡិចត្រូនិកទាំងអស់ ដែលម្ចាស់បណ្តឹងឧទ្ធរណ៍បានផ្តល់ឱ្យអ.វ.ត.ក រួមទាំងអាសយដ្ឋានសារអេឡិចត្រូនិករបស់មេធាវីជាតិរបស់គាត់ផងដែរ ប៉ុន្តែក្រឡាបញ្ជីមិនដែលបានទទួលការបញ្ជាក់អំពីការទទួលបានសេចក្តីជូនដំណឹងនោះទេ ហើយម្ចាស់បណ្តឹងឧទ្ធរណ៍ ក៏មិនបានដាក់ពាក្យជាផ្លូវការមកអង្គបុរេជំនុំជម្រះសុំដកបណ្តឹងឧទ្ធរណ៍នោះដែរ។ អង្គបុរេជំនុំជម្រះយល់ឃើញថា ឯកសាររបស់ម្ចាស់បណ្តឹងឧទ្ធរណ៍នោះ មិនស្របតាមវិធានផ្ទៃក្នុង និងសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅ អ.វ.ត.ក ឡើយ។ អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះនៅតែទទួលដោះស្រាយបណ្តឹងឧទ្ធរណ៍នេះដដែល។

## II. **ការសម្តែងមតិយោបល់ និងសេចក្តីសន្និដ្ឋាន**

៨. ទោះបីមានការខិតខំប្រឹងប្រែងយ៉ាងណាក្តី អង្គបុរេជំនុំជម្រះមិនអាចរកសំឡេងគាំទ្រជាវិជ្ជមានពីចៅក្រមបួនរូបយ៉ាងតិច ដែលចាំបាច់ដើម្បីអាចចេញសេចក្តីសម្រេចមួយលើបញ្ហានានានៅក្នុងបណ្តឹងឧទ្ធរណ៍។ ដោយហេតុថា វិធាន ៧៧(១៤) នៃវិធានផ្ទៃក្នុងចែងថា សេចក្តីសម្រេចរបស់អង្គជំនុំជម្រះត្រូវមានសំអាងហេតុ ហេតុដូច្នេះទើបមតិយោបល់របស់ចៅក្រមអង្គជំនុំជម្រះ ត្រូវបានដាក់ភ្ជាប់នឹងសេចក្តីពិចារណាទាំងនេះ។

៩. ដោយសារថា អង្គបុរេជំនុំជម្រះមិនអាចសម្រេចលើបណ្តឹងឧទ្ធរណ៍នេះ វិធាន ៧៧(១៣) កំណត់ថា ដីកាសម្រេចដែលត្រូវបានជំទាស់ ត្រូវបានតម្កល់ទុកជាបានការ។

## III. ការសម្រេចសេចក្តី

**អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះសូម៖**

ប្រកាសជាឯកច្ឆន្ទថា អង្គបុរេជំនុំជម្រះមិនអាចរកសំឡេងគាំទ្រជាវិជ្ជមានពីចៅក្រមបួនរូបយ៉ាងតិច ក្នុងការចេញសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍នេះបានឡើយ។

ដោយអនុលោមតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង ភាគីមិនមានលទ្ធភាពប្តឹងតវ៉ាទេ។

**ភ្នំពេញ, ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០១២**

**ប្រធាន** **អង្គបុរេជំនុំជម្រះ**

**ប្រាក់ គឹមសាន** **Rowan DOWNING** **នុំយ ថុល** **Katinka LAHUIS** **ហួត វុទ្ធី**

ចៅក្រម ប្រាក់ គឹមសាន ចៅក្រម ន័យ ថុល និង ចៅក្រម ហួត វុទ្ធី សូមដាក់ភ្ជាប់មតិយោបល់របស់ខ្លួន។

ចៅក្រម Downing និង ចៅក្រម Lahuis សូមដាក់ភ្ជាប់មតិយោបល់របស់ខ្លួន។

# យោបល់របស់ចៅក្រម ប្រាក់ គីមសាន ចៅក្រម ន៉ី ថុល និងចៅក្រម ហួត វុទ្ធី

១. អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ("អ្នកដាក់ពាក្យសុំ") [redacted] បានដាក់ពាក្យបណ្ដឹង[១] ដើម្បីចូលរួមក្នុងសំណុំរឿង ០០៣ និងបានស្នើសុំដាក់បញ្ចូលពត៌មាននៅក្នុងពាក្យសុំនៅក្នុងសំណុំរឿង ០០២ (VU Reg#00-VU-00013/Doc N0 D22/0001) ទៅក្នុងពាក្យសុំនេះ ។ លើសពីនេះទៅទៀត អ្នកដាក់ពាក្យសុំបានដាក់ភ្ជាប់ផងដែរ នូវសេចក្ដីដកស្រង់ពីសៀវភៅ ឆ្នាំ ២០០១ របស់លោក Stephen Heder និងលោក Brian D. Tittemore entiled "*Seven Candidates for Prosecution: Accountability for the crimes of the Khmer Rouge to her application*"។ អ្នកដាក់ពាក្យសុំបានលើកឡើងថា ខ្លួនមានអាយុ ៤ ទៅ ៨ ឆ្នាំ នៅក្នុងរបបខ្មែរក្រហម ខ្លួនជាជនរងគ្រោះ ដោយសារការផ្លាស់ទីប្រជាជនដោយបង្ខំពីភ្នំពេញ (***ដំណាក់កាលទី ១***) ការផ្លាស់ទីប្រជាជនដោយបង្ខំពីភូមិភាគបូព៌ា (***ដំណាក់កាលទី ៣***) ដែលនៅពេលនោះ ខ្លួនបានទទួលរងដូចជា មានការចាប់ខ្លួនដោយខុសច្បាប់ និងការឃុំខ្លួន នៅមន្ទីរសន្តិសុខវត្តធ្លក (ស្ថិតនៅភូមិធ្លក ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង ភូមិភាគបូព៌ា) និងក្រោយមកត្រូវបានបញ្ជូនទៅមន្ទីរសន្តិសុខបឹងរ៉ៃ ខ្លួនត្រូវបានបង្ខំឱ្យធ្វើការជាទម្ងន់ ឈឺចាប់ដោយការស្លាប់ម្ដាយរបស់ខ្លួន ហើយខ្លួនបានឃើញ និងបានទទួលរងការឈឺចាប់ដោយសារការសម្លាប់ស្ត្រីជាច្រើនដែលគ្មានកំហុស និងការសម្លាប់អ្នកទោសជាច្រើននាក់ទៀត នៅក្នុងមន្ទីរសន្តិសុខទាំងពីរ នៅក្នុងកំឡុង***ពេលបោសសំអាតភូមិភាគបូព៌ា*** ។ អ្នកដាក់ពាក្យសុំបានអះអាងផងដែរថា ខ្លួនជាជនរងគ្រោះ និងបានឃើញនូវឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលមន្ត្រីនៃរបប លន់ នល់ ជាកម្មវត្ថុនៃឧក្រិដ្ឋកម្មនោះ ។ លោកស្រីថា នៅក្នុងរបបនោះ ខ្លួនបានបាត់បង់ និងរងការឈឺចាប់ ដូចតទៅ ៖

. បានបាត់បង់ឪពុក ឈ្មោះ កែវ អ៊ឹម ដែលជាអតីតមេបញ្ជាការយោធា ដែលត្រូវបានបាត់ខ្លួនដោយបង្ខំ និងត្រូវបានសម្លាប់ ។

. ខ្លួន និងគ្រួសារ ត្រូវបានជម្លៀសដោយបង្ខំពីក្រុងភ្នំពេញ ទៅកាន់ខេត្ត ស្វាយរៀង ។

. ត្រូវបានឃុំខ្លួន នៅមន្ទីរសន្តិសុខ វត្តធ្លក អស់រយៈពេល ប្រហែល ៥ ទៅ ៦ ខែ ។

. ត្រូវបានដកហូតសិទ្ធិទទួលបានម្ហូបអាហារ ថ្នាំសង្កូវ ការអប់រំ និងគ្រឿងចាំបាច់ដទៃទៀត។

[១] ពាក្យបណ្ដឹងរបស់លោកស្រី [redacted] D១១/១/១។

. ទទួលរងនូវទារុណកម្ម និងការប្រព្រឹត្តមកលើផ្សេងៗទៀត ដោយឃោឃៅ និងអមនុស្សធម៌។

. បានឃើញអ្នកទោសដទៃទៀត ត្រូវមន្ត្រីខ្មែរក្រហមធ្វើទារុណកម្ម និង/ឬសម្លាប់។

. បានឃើញម្តាយខ្លួន ត្រូវបានធ្វើទារុណកម្ម ឬប្រព្រឹត្តមកលើដោយឃោរឃៅ និងអមនុស្សធម៌។

. បានបាត់បង់ម្តាយដែលជាជនរងគ្រោះនៃការបាត់ខ្លួនដោយបង្ខំ និងត្រូវបានសម្លាប់។

អ្នកដាក់ពាក្យសុំ [redacted] ក៏បានលើកឡើងដូចគ្នាផងដែរនៅក្នុងបណ្តឹងឧទ្ធរណ៍[២] ប្រឆាំងនឹងដីកាសម្រេចស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ថា [redacted] ត្រូវទទួលខុសត្រូវរួមគ្នា ផ្ទាល់លើព្យសនកម្មផ្លូវច្បាប់របស់ខ្លួន ក្នុងពេលជួលរលំ និងការចាកចេញទាំងហ្វូងពីទីក្រុងភ្នំពេញ (*ការផ្លាស់ទីលំនៅដំណាក់កាលទី I*) នៅពេលឪពុករបស់ខ្លួនដែលជាមេបញ្ជាការយោធា លន់ នល់ "បានបាត់ខ្លួន" នៅក្នុងចំណោមព្យសនកម្មផ្លូវច្បាប់នានាផ្សេងទៀត និងការផ្លាស់ទីលំនៅប្រជាជនភូមិភាគបូព៌ា (*ការផ្លាស់ទីលំនៅដំណាក់កាលទី III*) នៅពេលខ្មែរក្រហមបានឃុំឃាំងខ្លួន និងក្រុមគ្រួសាររបស់ខ្លួន ដំបូងនៅវត្តធ្លក និងបន្ទាប់មកនៅមន្ទីរសន្តិសុខបឹងរ៉ៃ (Boeung Rai) ដែលជាទីកន្លែងដែលគាត់មានពិសោធន៍ និងបានឃើញការស្លាប់ម្តាយរបស់ខ្លួន ក្នុងចំណោមប្រជាជន ៣០.០០០ (បីម៉ឺន)នាក់ដែលត្រូវបានសន្មត់ថា ត្រូវមានសម្លាប់ចោលនៅបឹងរ៉ៃ ។

២. អង្គហេតុដែលអ្នកដាក់ពាក្យសុំ [redacted] បានលើកឡើង នៅក្នុងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១១ សុទ្ធតែជាអង្គហេតុដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទី ១[៣] ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០៧ រួចហើយ គឺ ៖

- សេចក្តីសង្ខេប នៃអង្គហេតុ (កថាខណ្ឌទី១ ដល់ ទី៣៦)។
- ការជម្លៀសដោយបង្ខំ (កថាខណ្ឌទី ៣៧ ដល់ ទី ៤២)។
- ការធ្វើពលកម្មដោយបង្ខំ ស្ថានភាពរស់នៅអមនុស្សធម៌ និងការឃុំខ្លួនដោយខុសច្បាប់ (កថាខណ្ឌទី ៤៣ ដល់ ទី ៤៨)។

---

[២] កថាខណ្ឌទី ១៣ នៃ បណ្តឹងឧទ្ធរណ៍ D១១/១/៤/១ ។

[៣] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ លេខ D៣។

- ការសម្លាប់ ការធ្វើទារុណកម្ម និងការរំលោភបំពានផ្នែករាងកាយ និងផ្លូវចិត្ត ( កថាខណ្ឌទី ៤៩ និង ទី ៥៥ ) តំបន់ភ្នំពេញ។
- តំបន់ស្វាយរ៉ែត កំពង់សោម (កថាខណ្ឌទី ៥៩)។
- ភូមិភាគឧត្តរចាស់ ភូមិភាគបូព៌ា។

ព្រមទាំងនៅក្នុងដីកាដំណោះស្រាយនៃសំណុំរឿងលេខ០០២/១៩-០៩-២០០៧/អ.វ.ត.ក/ក.ស.ច.ស[៤]។

៣. ម្យ៉ាងទៀត យើងយល់ឃើញថា អង្គហេតុដែលបានរៀបរាប់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី២ ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ដែលបង្កើតបានជាសំណុំរឿង ០០៣ សុទ្ធតែអង្គហេតុចាស់ដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទី ១ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០៧។

៤. នៅក្នុងអំឡុងពេលនៃកិច្ចស៊ើបសួររបស់ខ្លួនក្នុងសំណុំរឿង ០០៣ ចាប់ពីពេលបើកការស៊ើបសួររហូតដល់ពេលជូនសំណើងពីការបិទការស៊ើបសួរ សហចៅក្រមស៊ើបអង្កេតមិនទាន់បានដាក់ជនណាម្នាក់ឲ្យស្ថិតនៅក្រោមការពិនិត្យនោះទេ មានន័យថា ក្នុងអង្គហេតុដែលសហព្រះរាជអាជ្ញាបញ្ជូនមកសហចៅក្រមស៊ើបអង្កេតតាមរយៈដីកាសន្និដ្ឋានបញ្ជូនឲ្យស៊ើបសួរនោះ គ្មានជនសង្ស័យណាម្នាក់ដែលសហចៅក្រមស៊ើបអង្កេតរកឃើញថាមានតម្រុយជាក់លាក់ និងស៊ីសង្វាក់ថាបានចូលរួមក្នុងការប្រព្រឹត្តបទល្មើសដូចដែលបានចោទប្រកាន់នោះទេ។

៥. ដូច្នេះ ការបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ក្នុងដំណាក់កាលនេះមិនធ្វើឲ្យប៉ះពាល់សិទ្ធិរបស់អ្នកដាក់ពាក្យសុំ [redacted] ឡើយ ។ លើសពីនេះទៅទៀត យើងយល់ឃើញថា ៖

៦. តាមគោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់ គឺសហព្រះរាជអាជ្ញាត្រូវធ្វើការវិនិច្ឆ័យលើអង្គហេតុដែលមានលក្ខណៈជាបទល្មើស និងមានជំរើសថា តើត្រូវធ្វើការចោទប្រកាន់ ឬតម្កល់រឿងទុកមិនចាត់ការ ទោះបីអង្គហេតុនោះជាបទល្មើសក៏ដោយ។ តាមគោលការណ៍នេះ សហចៅក្រមស៊ើបអង្កេតត្រូវធ្វើការស៊ើបសួរ តាមអង្គហេតុដែលសហព្រះរាជអាជ្ញាប្តឹងមកខ្លួន ដោយធ្វើការវាយតម្លៃលើភស្តុតាងដាក់បន្ទុកទាំងឡាយ ដែលសហព្រះរាជអាជ្ញាបានបញ្ជូនមកភ្ជាប់

[៤] ដីកាដំណោះស្រាយ D៤២៧ កថាខណ្ឌទី ២២១ ដល់ ២៨២ និងកថាខណ្ឌទី ៦៤៤ ដល់ ៦៦៦

ជាមួយនឹងសំណុំរឿង និងភស្តុតាងដោះបន្ទុកដែលខ្លួនទទួលបានបន្ថែមទៀត នៅក្នុងពេលដែលខ្លួនបានធ្វើការស៊ើបសួរ ព្រមទាំងភាពស៊ីសង្វាក់ដែលសង្ស័យថា បុគ្គលណាមួយបានប្រព្រឹត្តបទល្មើស។ ជាក់ស្តែង មាត្រា ៥៥(២) នៃវិធានផ្ទៃក្នុង តម្រូវឱ្យសហចៅក្រមស៊ើបអង្កេតត្រូវធ្វើការស៊ើបសួរតែអង្គហេតុណា ដែលមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម។

៧. វិធាន ៥៥(៤) នៃវិធានផ្ទៃក្នុង ដែលចែងថា សហចៅក្រមស៊ើបអង្កេត ***មានអំណាចបើកការស៊ើបសួរ ប្រឆាំងនឹងជនទាំងឡាយដែលមានឈ្មោះក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។*** សហចៅក្រមស៊ើបអង្កេតអាចបើកកិច្ចស៊ើបសួរផងដែរ ចំពោះបុគ្គលគ្រប់រូបដែលមានតម្រុយច្បាស់លាស់ និងស៊ីសង្វាក់ បញ្ជាក់ថា បុគ្គលនោះអាចជាអ្នកទទួលខុសត្រូវក្នុងការប្រព្រឹត្តបទឧក្រិដ្ឋ ដែលមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ទោះបីជាបុគ្គលទាំងនោះមិនមានឈ្មោះក្នុងដីកាក៏ដោយ។ ក្នុងករណីចុងក្រោយនេះ សហចៅក្រមស៊ើបអង្កេតត្រូវសួរយោបល់សហព្រះរាជអាជ្ញា មុនពេលដាក់បុគ្គលនោះឱ្យស្ថិតនៅក្រោមការពិនិត្យ។

៨. ពាក្យថា "*មានអំណាចបើកការស៊ើបសួរ*" នៅក្នុងវិធាន **៥៥(៤)** នេះ បង្ហាញច្បាស់ថា វិធានបានផ្តល់ឆន្ទានុសិទ្ធិឱ្យសហចៅក្រមស៊ើបអង្កេត ក្នុងការសម្រេចដាក់អោយស្ថិតក្រោមការពិនិត្យរបស់ខ្លួននូវជនទាំងឡាយដែលមានឈ្មោះក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងមានអំណាចបើកការស៊ើបសួរផងដែរ ចំពោះជនផ្សេងទៀត ដែលគ្មានឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ បញ្ញត្តិនេះមិនបានចាប់បង្ខំឱ្យសហចៅក្រមស៊ើបអង្កេត ត្រូវតែដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យនូវបុគ្គលគ្រប់រូប ដែលមានឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់សហព្រះរាជអាជ្ញានោះទេ។ម្យ៉ាងទៀត ***តាមមាត្រា ៥៥ (៥)*** ក៏គ្រាន់តែទុកសិទ្ធិឱ្យសហចៅក្រមស៊ើបអង្កេតសម្រេចថា តើគួរកោះហៅ ឬមិនកោះហៅជនសង្ស័យ ឬជនត្រូវចោទមកសួរចម្លើយតែប៉ុណ្ណោះ។

៩. មានន័យថា នៅពេលដែលសហព្រះរាជអាជ្ញាបញ្ជូនដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដោយស្នើសុំដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ ឬស្នើសុំឱ្យឃុំខ្លួនបណ្តោះអាសន្នលើឈ្មោះបុគ្គលណាមួយជាក់លាក់នោះ សហចៅក្រមស៊ើបអង្កេតមានឆន្ទានុសិទ្ធិក្នុងការសម្រេចដាក់ ឬមិនដាក់បុគ្គលនោះ ឱ្យ

00785034



ស្ថិតនៅក្រោមការពិនិត្យ ឬឃុំខ្លួនបណ្ដោះអាសន្ន។ ដូច្នេះ ចំពោះឈ្មោះជនត្រូវចោទដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមនោះ សហចៅក្រមស៊ើបអង្កេតមិនជាប់កាតព្វកិច្ចធ្វើតាមអ្វីដែលសហព្រះរាជអាជ្ញាប្ដឹងមកនោះទេ។ ដូច្នេះ ការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យជាសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេត។

១០. តាមវិធាន ៥៧ (១)៖ នៅពេលជនត្រូវចោទចូលបង្ហាញខ្លួន ចំពោះមុខសហចៅក្រមស៊ើបអង្កេតជាលើកដំបូង សហចៅក្រមស៊ើបអង្កេតត្រូវកត់ត្រាទុកនូវអត្តសញ្ញាណរបស់ជននោះ និងប្រាប់ជននោះអំពីបទចោទប្រកាន់ និងអំពីសិទ្ធិមានមេធាវី និងសិទ្ធិក្នុងការនៅស្ងៀមមិនឆ្លើយនឹងសំណួរ។ បញ្ញត្តិនេះ គ្រាន់តែបញ្ញត្តិអំពីសិទ្ធិការពារខ្លួនរបស់ជនជាប់ចោទតែប៉ុណ្ណោះ (***សិទ្ធិទទួលដំណឹងពីបទចោទប្រកាន់ សិទ្ធិមានមេធាវី និងសិទ្ធិក្នុងការនៅស្ងៀមមិនឆ្លើយនឹងសំណួរ***) នៅពេលដែលខ្លួនត្រូវមកបង្ហាញខ្លួន នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ទោះបីជាបង្ហាញខ្លួនដោយខ្លួនឯងតាមរយៈដីកាបង្គាប់ឱ្យចូលខ្លួន ឬដោយបង្ខំ តាមរយៈដីកាបង្គាប់ឱ្យចាប់ខ្លួនក៏ដោយ។ បញ្ញត្តិនេះមិនតម្រូវឱ្យសហចៅក្រមស៊ើបអង្កេត ដាច់ខាតត្រូវតែធ្វើការបង្គាប់ឱ្យជនត្រូវចោទចូលមកបង្ហាញខ្លួននៅពេលសហចៅក្រមស៊ើបអង្កេតបានទទួលដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនោះទេ ពោលគឺមិនកំណត់ថា នៅពេលណាមួយជាក់លាក់នោះឡើយ។

១១. ការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ គឺធ្វើឡើងប្រឆាំងចំពោះបុគ្គលណាម្នាក់នៅពេលដែលសហចៅក្រមស៊ើបអង្កេតមានតម្រុយច្បាស់លាស់ ហើយស៊ីសង្វាក់យ៉ាងខ្លាំងថា ជននោះបានចូលរួមប្រព្រឹត្តបទល្មើស ក្នុងឋានៈជាចារី ឬ ជាអ្នកសមគំនិត។

១២. ដូចដែលបានលើកក្នុងកថាខណ្ឌទី ៤ ខាងលើ នៅក្នុងអំឡុងពេលនៃកិច្ចស៊ើបសួររបស់ខ្លួន ក្នុងសំណុំរឿង ០០៣ ចាប់ពីពេលបើកការស៊ើបសួរ រហូតដល់ពេលជូនសំណើងពីការបិទការស៊ើបសួរ សហចៅក្រមស៊ើបអង្កេតមិនទាន់បានដាក់ជនណាម្នាក់ឱ្យស្ថិតនៅក្រោមការពិនិត្យនោះទេ មានន័យថា ក្នុងអង្គហេតុដែលសហព្រះរាជអាជ្ញាបញ្ជូនមកសហចៅក្រមស៊ើបអង្កេត តាមរយៈដីកាសន្និដ្ឋានបញ្ជូនឱ្យស៊ើបសួរនោះ គ្មានជនសង្ស័យណាម្នាក់ដែលសហចៅក្រមស៊ើបអង្កេតរកឃើញថាមានតម្រុយជាក់លាក់ និងស៊ីសង្វាក់ថាបានចូលរួមក្នុងការប្រព្រឹត្តបទល្មើសដូចដែលបានចោទប្រកាន់នោះទេ។

១៣. យោងតាមការបកស្រាយខាងលើ យើងយល់ឃើញថា មកទល់នឹងពេលចេញ ដីកាដែលរងការប្តឹងជំទាស់នឹងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់អ្នកដាក់ពាក្យសុំ [redacted] ក្នុងសំណុំរឿង០០៣ នេះ អង្គហេតុដែលបានប្តឹងមកសហចៅក្រមស៊ើបអង្កេត តាមដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរនោះ សហចៅក្រមស៊ើបអង្កេតមិនទាន់អាចកំណត់ឈ្មោះជនត្រូវចោទបាននៅឡើយ។

១៤. ម្យ៉ាងទៀត ការប្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីធ្វើឡើងក្នុងគោលបំណងឲ្យទទួលបាននូវការជួសជុលការខូចខាតដែលបណ្តាលមកពីអំពើល្មើសដល់ភាគីរងគ្រោះ។ អំពើល្មើសនោះ ត្រូវកើតឡើងដោយផ្ទាល់ពីអំពើរបស់ជនល្មើស រួមមាន ចារី សហចារី។ល។

១៥. យើងយល់ឃើញថា កាលបើពុំមានជនត្រូវចោទដែលត្រូវទទួលខុសត្រូវក្នុងការជួសជុលការខូចខាតបណ្តាលមកពីអំពើល្មើសរបស់ខ្លួនលើជនរងគ្រោះទេនោះ ការបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ក្នុងដំណាក់កាលនេះ មិនធ្វើឲ្យប៉ះពាល់ដល់សិទ្ធិជនរងគ្រោះឡើយ[៥]។

ភ្នំពេញ ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០១២

ប្រាក់ គឹមសាន ន៉ីយ ថុល ហួត វុទ្ធី

[៥] វិធាន ២៣ ស្ទួនបួន នៃវិធានផ្ទៃក្នុង ។

# មតិយោបល់របស់ចៅក្រម DOWNING និងចៅក្រម LAHUIS

## I - សេចក្តីសង្ខេបនៃសារណា

១. បណ្តឹងឧទ្ធរណ៍នេះត្រូវបានដាក់ដោយអនុលោមតាមវិធាន ៧៤(៤)(ខ) និងវិធាន ៧៧*ស្ទួន* នៃវិធានផ្ទៃក្នុង[១]។ ម្ចាស់បណ្តឹងឧទ្ធរណ៍បានដាក់ជូនសំណើសុំចំនួន ៣ ដោយស្នើសុំអង្គបុរេជំនុំជម្រះឲ្យប្រកាសទទួលយកបណ្តឹងឧទ្ធរណ៍នេះ ច្រានចោលសេចក្តីសម្រេចនៅក្នុងដីកាសម្រេចដែលត្រូវបានជំទាស់ និងផ្តល់ឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០៣ ដល់ម្ចាស់បណ្តឹងឧទ្ធរណ៍វិញ។ ដើម្បីជាមូលដ្ឋានគាំទ្រលើបណ្តឹងឧទ្ធរណ៍នេះ ម្ចាស់បណ្តឹងឧទ្ធរណ៍បានលើកឡើងមូលដ្ឋានចំនួន ៤ ដូចខាងក្រោម៖

**មូលដ្ឋានទី១**[២]៖ សហចៅក្រមស៊ើបអង្កេតបានរំលោភបំពានលើវិធាន ៥៦ និងវិធាន ២១ នៃវិធានផ្ទៃក្នុង ដោយបានដកហូតភាពយុត្តិធម៌ផ្នែកនីតិវិធី ដែលធានាដល់ការទទួលបានព័ត៌មានលើវិសាលភាពនៃកិច្ចស៊ើបសួរ ឲ្យបានគ្រប់គ្រាន់ និងទាន់ពេលវេលា។ ជាពិសេស ម្ចាស់បណ្តឹងឧទ្ធរណ៍បានលើកឡើងថា នៅពេលខកខានពុំបានជូនដំណឹងឲ្យបានសមស្របអំពីវិសាលភាពនៃកិច្ចស៊ើបសួរលើសំណុំរឿង ០០៣ ដល់សាធារណៈជន ជនរងគ្រោះ និងអ្នកដែលអាចនឹងក្លាយជាដើមបណ្តឹងរដ្ឋប្បវេណីបែបនេះ សហចៅក្រមស៊ើបអង្កេតបានរំលោភបំពានលើកាតព្វកិច្ចរបស់ខ្លួនដូចមានចែងនៅក្នុងវិធាន ២១(១)(គ) នៃវិធានផ្ទៃក្នុង ព្រមទាំងគោលការណ៍ទូទៅនៅក្នុងមាត្រា ៦ នៃគោលការណ៍មូលដ្ឋានសម្រាប់ជនរងគ្រោះ[៣] ដើម្បីធ្វើយ៉ាងណាឲ្យជនរងគ្រោះទទួលបានការជូនដំណឹង និងទទួលបានការគោរពសិទ្ធិ "នៅក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធី"។ ម្ចាស់បណ្តឹងឧទ្ធរណ៍ទទួលស្គាល់ថា កិច្ចស៊ើបសួរត្រូវរក្សាការសម្ងាត់ ក៏ប៉ុន្តែអះអាងថា សហចៅក្រមស៊ើបអង្កេតបានអនុវត្តគោលការណ៍រក្សាការសម្ងាត់ ដោយពុំសមហេតុផលនៅក្នុងសំណុំរឿង ០០៣ នេះ ហើយការពុំមានព័ត៌មានទាំងនេះបានបណ្តាលឲ្យមានភាពអយុត្តិធម៌ផ្នែកនីតិវិធី ដោយហេតុថាខ្លួនពុំទទួលបានសិទ្ធិចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីដោយប្រសិទ្ធភាព និងពុំទទួលបានការគាំទ្រ

---

[១] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ១៨។

[២] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ២១-៣៣។

[៣] មហាសន្និបាតអង្គការសហប្រជាជាតិ សេចក្តីប្រកាសស្តីពីគោលការណ៍មូលដ្ឋាននៃយុត្តិធម៌សម្រាប់ជនរងគ្រោះនៃឧក្រិដ្ឋកម្ម និងការរំលោភបំពានអំណាច សេចក្តីសម្រេចលេខ ៤០/៣៤ ចុះថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ១៩៨៥។

លើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ខ្លួននៅក្នុងរឿងក្តីនេះ។

**មូលដ្ឋានទី២**[៤]៖ ការសម្រេចបដិសេធលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០៣ បានកើតចេញពីការខកខានរបស់សហចៅក្រមស៊ើបអង្កេតនៅក្នុងការស៊ើបអង្កេតដោយឯករាជ្យ និងត្រឹមត្រូវលើអង្គហេតុនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទី២ ដែលវាផ្ទុយនឹងមាត្រា ៥(២) និង(៣) នៃកិច្ចព្រមព្រៀង មាត្រា ១០ ថ្មី នៃច្បាប់ អ.វ.ត.ក និងវិធាន ១៤ (១) និងវិធាន ៥៥(៥) នៃវិធានផ្ទៃក្នុង។ ជាពិសេស ម្ចាស់បណ្តឹងឧទ្ធរណ៍បានចោទប្រកាន់ថា សហចៅក្រមស៊ើបអង្កេតខកខានមិនបានបំពេញកាតព្វកិច្ច និងមុខនាទីតាមផ្លូវច្បាប់របស់ខ្លួន ដោយមិនបានចុះស៊ើបអង្កេតដល់ទីកន្លែងពោលគឺ ទីតាំងឧក្រិដ្ឋកម្ម និងហេតុការណ៍នៃឧក្រិដ្ឋកម្ម ដែលពាក់ព័ន្ធនឹងសំណុំរឿង ០០៣ ជាពិសេស ដោយសារតែសំណុំរឿង ០០៣ នេះ ពាក់ព័ន្ធនឹងអង្គហេតុដែលម្ចាស់បណ្តឹងឧទ្ធរណ៍បានលើកឡើងនៅក្នុងពាក្យសុំ។ ម្ចាស់បណ្តឹងឧទ្ធរណ៍បានអះអាងថា ការខកខានបែបនេះប៉ះពាល់ជាអវិជ្ជមានដល់លទ្ធភាពរបស់ខ្លួន នៅក្នុងការរៀបចំពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីឲ្យមានលក្ខណៈរឹងមាំជាងនេះ ហើយនៅចុងក្រោយ នាំឲ្យសហចៅក្រមស៊ើបអង្កេត សម្រេចបដិសេធលើពាក្យសុំរបស់ខ្លួនចោល។

**មូលដ្ឋានទី៣**[៥]៖ សហចៅក្រមស៊ើបអង្កេតបានអនុវត្ត និងបកស្រាយដោយពុំត្រឹមត្រូវលើអង្គហេតុ និងអង្គច្បាប់ ដែលពាក់ព័ន្ធនឹងការចូលរួមរបស់ [redacted] នៅក្នុងសហឧក្រិដ្ឋកម្មរួម (សហឧក្រិដ្ឋកម្មរួម) ព្រមទាំងគោលបំណង និងគម្រោងរួម។ ជាពិសេស ម្ចាស់បណ្តឹងឧទ្ធរណ៍ចង្អុលបញ្ជាក់ថា ការទទួលស្គាល់ម្ចាស់បណ្តឹងឧទ្ធរណ៍ជាដើមបណ្តឹងរដ្ឋប្បវេណី អនុលោមតាមវិធាន ២៣*ស្ទួន* នៃវិធានផ្ទៃក្នុង ទាមទារឲ្យម្ចាស់បណ្តឹងឧទ្ធរណ៍ភ្ជាប់ទំនាក់ទំនងនៃព្យសនកម្មរបស់ខ្លួនជាមួយនឹង "ឧក្រិដ្ឋកម្មណាមួយ" នៃឧក្រិដ្ឋកម្ម ដែលត្រូវបានចោទប្រកាន់លើជនជាប់ចោទតែប៉ុណ្ណោះ។ ម្ចាស់បណ្តឹងឧទ្ធរណ៍ស្នើឡើងថា សហចៅក្រមស៊ើបអង្កេតមានការភាន់ច្រឡំនៅក្នុងរឿងក្តីនេះ ដោយបានអនុវត្តលក្ខខណ្ឌចំណងហេតុផលទៅនឹងស្រុក និងភូមិភាគនៃទីតាំងភូមិសាស្ត្រ ដែល [redacted] ពោលគឺមិនភ្ជាប់ទំនាក់ទំនងនេះទៅនឹងឧក្រិដ្ឋកម្មទាំងឡាយ ដែលត្រូវបានចោទប្រកាន់ថា ជនទាំងពីរនេះជាអ្នកប្រព្រឹត្តតាមរយៈការចូលរួមនៅក្នុងសហឧក្រិដ្ឋកម្មរួម អនុលោមតាមដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទី២ឡើយ ហើយ

[៤] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៣៤-៤៩។

[៥] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៥០-៥៤។

**មូលដ្ឋានទី៤**[៦]**៖** សហចៅក្រមស៊ើបអង្កេតខកខានមិនបានចេញសេចក្ដីសម្រេចដែលមានសំអាងហេតុស្ដីពីការមិនទទួលស្គាល់ពាក្យសុំរបស់ម្ចាស់បណ្ដឹងឧទ្ធរណ៍ ដែលជាហេតុនាំឱ្យមានការរំលោភបំពានលើវិធាន ២១ នៃវិធានផ្ទៃក្នុង និងមាត្រា ៤ នៃគោលការណ៍មូលដ្ឋានសម្រាប់ជនរងគ្រោះ។ ម្ចាស់បណ្ដឹងឧទ្ធរណ៍បានអះអាងថា ការខកខានរបស់សហចៅក្រមស៊ើបអង្កេតមិនបានចេញសេចក្ដីសម្រេចដែលមានសំអាងហេតុត្រឹមត្រូវមួយ គឺជាការរំលោភបំពានលើកាតព្វកិច្ចរបស់ខ្លួនក្នុងការធានានូវតម្លាភាព និងសច្ចភាពតាមផ្លូវច្បាប់ ក្នុងការជូនដំណឹងដល់ជនរងគ្រោះឱ្យបានសមរម្យ នៅក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធី និងនៅក្នុងការសម្ដែងសេចក្ដីអាណិតអាសូរដល់ជនរងគ្រោះ និងការគោរពសេចក្ដីថ្លៃថ្នូររបស់ពួកគាត់។

## II - ភាពអាចទទួលយកបាននៃបណ្ដឹងឧទ្ធរណ៍

២. វិធាន ៧៤(៤)(ខ) និងវិធាន ៧៧*ស្ទួន* នៃវិធានផ្ទៃក្នុង អនុញ្ញាតឱ្យអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ធ្វើបណ្ដឹងឧទ្ធរណ៍ចំពោះមុខអង្គបុរេជំនុំជម្រះ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ដែលបានប្រកាសមិនទទួលស្គាល់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី។ វិធានទាំងនេះក៏បានចែងផងដែរថា បណ្ដឹងឧទ្ធរណ៍នេះត្រូវដាក់ក្នុងរយៈពេល ១០ ថ្ងៃ ក្រោយពីថ្ងៃជូនដំណឹងអំពីដីកាសម្រេចទទួលស្គាល់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី។ អនុលោមតាមវិធាន ៧៧ *ស្ទួន* នៃវិធានផ្ទៃក្នុង អង្គបុរេជំនុំជម្រះមានយុត្តាធិការពិចារណាលើកំហុសអង្គហេតុ និង/ឬកំហុសអង្គច្បាប់ នៅពេលសម្រេចលើការទទួលស្គាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ដែលបានធ្វើឡើងស្របតាមវិធាន ២៣*ស្ទួន*នៃវិធានផ្ទៃក្នុង។ ករណីនេះមានន័យថា បណ្ដឹងឧទ្ធរណ៍ដែលបានដាក់ប្ដឹងទៅអង្គបុរេជំនុំជម្រះស្របតាមវិធាន ៧៤(៤)(ខ) និងវិធាន ៧៧*ស្ទួន* នៃវិធានផ្ទៃក្នុង នឹងអាចទទួលយកបាន ដរាបណាបណ្ដឹងទាំងនេះបានតវ៉ាចំពោះការពិចារណារបស់សហចៅក្រមស៊ើបអង្កេត លើការទទួលស្គាល់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី និង/ឬវិធីសាស្ត្រ ដែលសហចៅក្រមស៊ើបអង្កេតបានចាត់ចែងជាទូទៅលើរបបនៃការទទួលស្គាល់ដើមបណ្ដឹងរដ្ឋប្បវេណី ដែលបានផ្ដល់ជូនដល់ជនរងគ្រោះ ក្រោមក្របខ័ណ្ឌគតិយុត្តរបស់ អ.វ.ត.ក។

[៦] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ៥៥-៦៦។

00785039



៣. នៅក្នុងរឿងក្តីនេះ ដីកាសម្រេចដែលត្រូវបានជំទាស់ ដោយបានសម្រេចបដិសេធលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០៣ របស់ម្ចាស់បណ្តឹងឧទ្ធរណ៍ ត្រូវបានសហចៅក្រមស៊ើបអង្កេតចេញនៅថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១ និងត្រូវបានជូនដំណឹងទៅសហមេធាវីជាតិរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ នៅថ្ងៃទី ៣ ខែ ឧសភា ឆ្នាំ ២០១១។ ដោយពិចារណាឃើញថា នៅថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០១១ គឺជាថ្ងៃឈប់សម្រាកផ្លូវការ ហេតុដូច្នេះ សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ និងសារណាលើបណ្តឹងឧទ្ធរណ៍ ដែលត្រូវបានដាក់រួមគ្នា នៅថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១១ ត្រូវបានដាក់ស្របពេលវេលាដែលមានចែងនៅក្នុងវិធាន ៧៥ និងវិធាន ៧៧*ស្ទួន* (២) នៃវិធានផ្ទៃក្នុង។

៤. ចំពោះយុត្តាធិការរបស់អង្គបុរេជំនុំជម្រះ យើងពិចារណាឃើញថា មូលដ្ឋានទី ១, ៣, និង ៤ នៃបណ្តឹងឧទ្ធរណ៍អាចទទួលយកបាន អនុលោមតាមវិធាន ៧៤(៤)(ខ) និងវិធាន ៧៧*ស្ទួន* នៃវិធានផ្ទៃក្នុង។ ក៏ប៉ុន្តែ មូលដ្ឋានទី ២ នៃបណ្តឹងឧទ្ធរណ៍ ពុំអាចទទួលយកបានឡើយ ដោយសារមូលដ្ឋាននេះប្តឹងលើកិច្ចស៊ើបសួរ ដែលសហចៅក្រមស៊ើបអង្កេតបានធ្វើឡើង ជាហេតុធ្វើឲ្យមូលដ្ឋានមួយនេះពុំស្ថិតនៅក្នុងវង្វង់នៃបញ្ញាណាមួយ ដែលមានចែងទុកនៅក្នុងវិធាន ៧៤(៤) នៃវិធានផ្ទៃក្នុងឡើយ។

## III - បទដ្ឋាននៃការពិនិត្យមើលឡើងវិញ

៥. ការរំលោភបំពានលើសិទ្ធិដែលម្ចាស់បណ្តឹងឧទ្ធរណ៍បានចោទប្រកាន់ ត្រូវបានយកមកពិនិត្យ ស្របតាមបទដ្ឋាននៃការពិនិត្យឡើងវិញលើបណ្តឹងឧទ្ធរណ៍ ដែលអង្គបុរេជំនុំជម្រះបានទទួលស្គាល់។ បទដ្ឋានទាំងនេះរួមមាន "ចំពោះបណ្តឹងឧទ្ធរណ៍ កំហុសលើអង្គច្បាប់ដែលបានលើកឡើងត្រូវបានពិនិត្យ*ជាថ្មីឡើងវិញ* ដើម្បីពិចារណាថាតើសេចក្តីសម្រេចផ្លូវច្បាប់មានលក្ខណៈត្រឹមត្រូវដែរឬអត់ ហើយកំហុសលើអង្គហេតុត្រូវបានពិនិត្យឡើងវិញ ស្របតាមបទដ្ឋានស្តីពីភាពសមស្របដើម្បីសម្រេចថាតើ អ្នកវិនិច្ឆ័យសេចក្តីទៅលើអង្គហេតុមិនប្រកបដោយហេតុផល ដែលអាចនាំឲ្យឈាន

ដល់ការសម្រេចទៅលើអង្គហេតុ ដែលបានលើកឡើងនេះដែរឬអត់”[៧]។

៦. នៅពេលពិចារណាលើចរិតលក្ខណៈនៃបញ្ហា ដែលបានលើកឡើងក្នុងសារណានៃបណ្ដឹងឧទ្ធរណ៍ យើងសូមយោងផងដែរទៅលើសេចក្ដីពិចារណារបស់អង្គបុរេជំនុំជម្រះនៅក្នុងសាលដីកាលើករណីដើមបណ្ដឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២ ទាក់ទិននឹងយុត្តាធិការដែលមានស្រាប់ដើម្បីពិនិត្យមើលគោលការណ៍នៃការបំពេញការងារដោយយកចិត្តទុកដាក់របស់សហចៅក្រមស៊ើបអង្កេត[៨]។ ក្នុងសាលដីកានោះ “អង្គបុរេជំនុំជម្រះ បានកត់សម្គាល់ថាសហចៅក្រមស៊ើបអង្កេត មិនបានជូនដំណឹងដល់ជនរងគ្រោះឱ្យបានទាន់ពេលវេលាឡើយ។ អង្គបុរេជំនុំជម្រះពិចារណាថា ការបង្ហាញពីការមិនយកចិត្តទុកដាក់ឱ្យបានត្រឹមត្រូវ ក្នុងការប្រព្រឹត្តរបស់សហចៅក្រមស៊ើបអង្កេតជាកត្តាពាក់ព័ន្ធមួយ នៅពេលដែលធ្វើការពិចារណានៅលើសិទ្ធិរបស់ជនរងគ្រោះក្នុងដំណើរការនីតិវិធី។ ហេតុដូច្នេះ ការពិនិត្យមើលទៅលើដំណាក់កាលនានាដែលសហចៅក្រមស៊ើបអង្កេតបានអនុវត្ត ព្រមទាំងការពិនិត្យមើលថាតើការអនុវត្តនេះប៉ះពាល់កម្រិតណាដែរ ចំពោះស្ថានភាពរបស់ជនរងគ្រោះ [ត្រូវបានយល់ឃើញថា] គឺជាការចាំបាច់[៩]។”

## VI - ការតវ៉ាច្រឡំ ដែលត្រូវបានចោទប្រកាន់នៅក្នុងមូលដ្ឋានទី១ នៃបណ្ដឹងឧទ្ធរណ៍

៧. ម្ចាស់បណ្ដឹងឧទ្ធរណ៍ជំទាស់ថា សហចៅក្រមស៊ើបអង្កេតបានរំលោភលើកាតព្វកិច្ចរបស់ខ្លួនដែលមានចែងក្នុងវិធាន ២១ (១) (គ) ដោយមិនបានផ្ដល់ព័ត៌មានឱ្យបានទាន់ពេល និងគ្រប់គ្រាន់ដល់ជនរងគ្រោះអំពីកិច្ចស៊ើបសួរ ដែលបណ្ដាលឱ្យមានភាពមិនយុត្តិធម៌ក្នុងនីតិវិធី និងរំលោភសិទ្ធិរបស់ជនរងគ្រោះ។

---

[៧] សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត លើការទទួលពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១១ ឯកសារ លេខD404/2/4 និង D411/3/6 (សាលដីកាលើករណីដើមបណ្ដឹងរដ្ឋប្បវេណី ក្នុងសំណុំរឿង០០២) កថាខណ្ឌរួម ៣៥។

[៨] សាលដីកាលើករណីដើមបណ្ដឹងរដ្ឋប្បវេណី ក្នុងសំណុំរឿង០០២ កថាខណ្ឌរួម ៥១-៥៣។

[៩] សាលដីកាលើករណីដើមបណ្ដឹងរដ្ឋប្បវេណី ក្នុងសំណុំរឿង០០២ កថាខណ្ឌរួម ៥១។



E.C.C.C. C.E.T.C. PRE-TRIAL CHAMBER PRELIMINAIRE

00785041



៨. ដូចអ្វីដែលម្ចាស់បណ្ដឹងបានលើកឡើង យើងកត់សម្គាល់ថា[១០] ផ្ទុយពីអ្វីដែលបានអនុវត្តកន្លងមកនៅក្នុងសំណុំរឿង ០០២[១១] ជនរងគ្រោះពុំទទួលបានព័ត៌មានណាមួយអំពីកិច្ចស៊ើបសួរក្នុងសំណុំរឿង ០០៣ ទេ ហើយក៏ពុំបានដឹងអំពីសិទ្ធិរបស់ខ្លួនក្នុងការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ឬដាក់បណ្ដឹងក្នុងរឿងក្ដីនេះ មុនពេលសហចៅក្រមស៊ើបអង្កេត សម្រេចបញ្ចប់កិច្ចស៊ើបសួរនៅថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១ នោះដែរ។ សហចៅក្រមស៊ើបអង្កេតគ្រាន់តែប្រកាសជាសាធារណៈនៅថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១ ថាខ្លួនបានចេញសេចក្ដីជូនដំណឹងអំពីការបញ្ចប់ការស៊ើបសួរហើយ ដោយមិនបានផ្ដល់ព័ត៌មានស្ដីពីវិសាលភាពនៃកិច្ចស៊ើបសួរ ឬព័ត៌មានដទៃទៀតទាល់តែសោះ។ ព័ត៌មានតែមួយគត់ដែលបានប្រកាសជាសាធារណៈអំពីវិសាលភាពនៃកិច្ចស៊ើបសួរក្នុងសំណុំរឿង ០០៣ នោះគឺព័ត៌មានដែលសហព្រះរាជអាជ្ញាអន្តរជាតិ[១២] បានផ្ដល់ឱ្យតាមរយៈសេចក្ដីប្រកាសព័ត៌មាននៅថ្ងៃទី ៩ ខែ ឧសភា ឆ្នាំ ២០១១ ដែលត្រូវបានសម្រេចឱ្យដកចេញវិញតាមរយៈដីកាចេញដោយសហចៅក្រមស៊ើបអង្កេត[១៣]។ ដោយអនុលោមតាមវិធានផ្ទៃក្នុង ជនរងគ្រោះមានរយៈពេល ១៥ ថ្ងៃ ក្នុងការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីបន្ទាប់ពីការចេញសេចក្ដីជូនដំណឹងអំពីការបញ្ចប់ការស៊ើបសួរ ហេតុនេះជាគោលការណ៍ ការដាក់ពាក្យត្រូវផុតកំណត់នៅថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១១[១៤]។ ដូចដែលបានគូសបញ្ជាក់រួចមក

---

[១០] សូមមើលផងដែរ សេចក្ដីពិចារណារបស់អបជ ពាក់ព័ន្ធនឹងបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចស្ដីពីការទទួលពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី របស់លោក [redacted] ចុះថ្ងៃទី ២៤ តុលា ២០១១ មតិយោបល់របស់លោកស្រីចៅក្រម Lahuis និងលោកចៅក្រម Downing ដែលហៅថា "មតិយោបល់ទាក់ទងនឹងបណ្ដឹងឧទ្ធរណ៍របស់ [redacted]" កថាខណ្ឌ ៤-៦។

[១១] ក្នុងសំណុំរឿង ០០២ សហចៅក្រមស៊ើបអង្កេត បានចេញសេចក្ដីប្រកាសព័ត៌មាននៅថ្ងៃទី ៥ ខែ វិច្ឆិកា ឆ្នាំ ២០០៩ បង្ហាញពីវិសាលភាពនៃកិច្ចស៊ើបសួរ និងជូនដំណឹងដល់ជនរងគ្រោះអំពីសិទ្ធិរបស់ពួកគាត់ក្នុងការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០២ រយៈពេលពីរខែមុនពេលបញ្ចប់កិច្ចស៊ើបសួរ (ថ្ងៃទី ១៤ ខែ មករាឆ្នាំ ២០១០)។ សហចៅក្រមស៊ើបអង្កេត ពន្យាកាលបរិច្ឆេទផុតពីរលើកឱ្យអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីដាក់ព័ត៌មានបន្ថែមដើម្បីគាំទ្រពាក្យសុំរបស់ខ្លួន។ ការពន្យាពេលនេះ មានរយៈពេល៥ខែ (រហូតដល់ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១០)។ ក្នុងសំណុំរឿង ០០២ អង្គបុរេជំនុំជម្រះ យល់ឃើញថាជនរងគ្រោះ មិនបានទទួលព័ត៌មានគ្រប់គ្រាន់ និងទាន់ពេល ដែលជាការរំលោភលើសិទ្ធិរបស់ជនរងគ្រោះ៖ *សូមមើល* សាលដីកាលើករណីដើមបណ្ដឹងរដ្ឋប្បវេណី ក្នុងសំណុំរឿង០០២ កថាខណ្ឌរួម ៥១-៥៤។

[១២] សេចក្ដីប្រកាសព័ត៌មាន៖ សេចក្ដីប្រកាសរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្ដីពីសំណុំរឿង ០០៣ ចុះថ្ងៃទី ៩ ខែ ឧសភា ឆ្នាំ ២០១១។

[១៣] ដីកាសម្រេចអំពីសេចក្ដីប្រកាសព័ត៌មានជាសាធារណៈរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទាក់ទងនឹងសំណុំរឿង ០០៣ (ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១១ ឯកសារលេខ D14)។

[១៤] វិធានផ្ទៃក្នុង ២៣ *ស្ទួន* (២)។

ហើយដោយអង្គបុរេជំនុំជម្រះនៅក្នុង "សាលដីការបស់ខ្លួនលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេតស្តីពីពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី" ក្នុងសំណុំរឿង ០០២ ដែលថាការជូនដំណឹងគ្រប់គ្រាន់ និងទាន់ពេលនូវវិសាលភាពនៃកិច្ចស៊ើបសួរជាប្រការសំខាន់សម្រាប់ជនរងគ្រោះអនុវត្តនូវសិទ្ធិដែលខ្លួនទទួលបានតាមវិធាន ២៣ ស្ទួន នៃវិធានផ្ទៃក្នុង[១៥]។ ជាពិសេស សម្រាប់ជនរងគ្រោះដែលដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងរឿងក្តីណាមួយ ពួកគាត់ត្រូវបង្ហាញ *ដែលក្នុងចំណោមនោះ* ពីទំនាក់ទំនងរវាងព្យសនកម្មដែលបានទទួលរង និងយ៉ាងហោចណាស់ក៏មានឧក្រិដ្ឋកម្មណាមួយ ក្នុងចំណោមឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ប្រឆាំងជនត្រូវចោទណាម្នាក់។ ការបង្ហាញបែបនេះ មិនអាចធ្វើបានទេនៅពេលដែលពុំមានព័ត៌មានណាមួយ ត្រូវបានផ្តល់ឲ្យដឹងនោះ។ ដោយសារក្នុងសំណុំរឿង ០០២ ព័ត៌មានជាច្រើន ត្រូវបានបង្ហាញឲ្យជនរងគ្រោះដឹងតាំងពីដំណាក់កាលដំបូងៗនោះ អង្គបុរេជំនុំជម្រះយល់ឃើញថាសហចៅក្រមស៊ើបអង្កេតបានរំលោភសិទ្ធិរបស់ជនរងគ្រោះ ក្នុងការដែលខ្លួនមិនបានផ្តល់ព័ត៌មានឲ្យបានពេញលេញដល់គាត់។ ផ្ទុយពីការអនុវត្តកន្លងមកក្នុងសំណុំរឿង ០០២ និងក្រៅពីក្របខ័ណ្ឌជាក់លាក់ដែលមានចែងក្នុងវិធានផ្ទៃក្នុង ជាពិសេសសិទ្ធិក្នុងការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងរឿងក្តីនានានៅ អ.វ.ត.ក សហចៅក្រមស៊ើបអង្កេតមិនបានផ្តល់ការពន្យល់ណាមួយទាល់តែសោះ ចំពោះការមិនបានផ្តល់ព័ត៌មានស្តីពីកិច្ចស៊ើបសួរដែលបានធ្វើក្នុងសំណុំរឿង ០០៣ ដល់ជនរងគ្រោះ និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលមានសក្តានុពលឡើយ។

៩. យើងសូមកត់សម្គាល់ថាមិនមានអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីណាម្នាក់បានអនុវត្តសិទ្ធិរបស់ខ្លួនប្រកបដោយប្រសិទ្ធិភាពក្នុងការចូលរួមក្នុងកិច្ចស៊ើបសួរ ដូចមានចែងយ៉ាងច្បាស់ក្នុងវិធានផ្ទៃក្នុងទេ[១៦] ហើយយើងក៏កត់សម្គាល់ផងដែរថា ស្ថានភាពនេះកើតឡើងភាគច្រើនដោយសារការមិនផ្តល់ព័ត៌មានជុំវិញកិច្ចស៊ើបសួរក្នុងសំណុំរឿង ០០៣។ ហេតុនេះ យើងយល់

---

[១៥] សាលដីកាលើករណីដើមបណ្តឹងរដ្ឋប្បវេណី ក្នុងសំណុំរឿង០០២ កថាខណ្ឌរួម ៥១-៥៤។

[១៦] សូមមើល *ក្នុងចំណោមនោះ* សិទ្ធិដែលផ្តល់ដល់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងកិច្ចស៊ើបសួរតាមវិធានផ្ទៃក្នុង វិធាន ៥៥ (៨) (ការចុះទៅដល់កន្លែងដោយសហចៅក្រមស៊ើបអង្កេត), វិធាន ៥៥ (១០) (សំណុំសុំបំពេញកិច្ចស៊ើបសួរ), វិធាន ៥៨ (៥) (ចូលរួមក្នុងការតទល់គ្នា) វិធាន ៥៩ (៥) (ស្នើសុំសហចៅក្រមស៊ើបអង្កេតស្តាប់ចម្លើយខ្លួន ស្តាប់ចម្លើយសាក្សី ចុះទៅដល់ទីកន្លែងកើតហេតុ បង្គាប់ឲ្យធ្វើកោសល្យវិច័យ ឬប្រមូលយកភស្តុតាងដទៃទៀត), វិធាន ៧៤ (៤) (ធ្វើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត) និងវិធាន ៧៦ (២) (ស្នើសុំធ្វើមោឃភាពផ្នែកណាមួយនៃកិច្ចដំណើរការនីតិវិធី)។

ថា សិទ្ធិរបស់ជនរងគ្រោះពុំត្រូវបានគេអើពើ និងត្រូវបានគេធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំង។ យើងក៏សូមសង្កត់ធ្ងន់ផងដែរថា ការអនុញ្ញាតឱ្យចូលរួមក្នុងកិច្ចស៊ើបសួរតាមបញ្ញត្តិដែលមានចែងក្នុងវិធានផ្ទៃក្នុងតាមរយៈរូបភាពផ្សេងៗនោះ ទោះបីក្នុងនាមជាអ្នកដាក់ពាក្យបណ្តឹងក្តី[១៧] ឬអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្តី ជនរងគ្រោះអាចនាំយកព័ត៌មានសំខាន់ៗ ពាក់ព័ន្ធនឹងអង្គហេតុដែលស្ថិតក្រោមកិច្ចស៊ើបសួរបាន រួមទាំងតួនាទីរបស់ជនសង្ស័យក្នុងឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់នោះផងដែរ។ ការបដិសេធមិនឱ្យជនរងគ្រោះបានចូលរួមក្នុងកិច្ចស៊ើបសួរ អាចធ្វើឱ្យសហចៅក្រមស៊ើបអង្កេតបាត់បង់នូវព័ត៌មានសំខាន់ៗក្នុងការស្វែងរកការពិត ដែលនាំឱ្យកិច្ចស៊ើបសួរនោះមិនបានពេញលេញ និងលេចឡើងនូវការសង្ស័យពីភាពមិនលំអៀងនៃកិច្ចស៊ើបសួរនេះ។

១០. ជាបញ្ហាទូទៅមួយ អង្គបុរេជំនុំជម្រះបានគូសបញ្ជាក់ហើយថា ចំពោះបទប្បញ្ញត្តិនៃវិធានផ្ទៃក្នុងដែលពាក់ព័ន្ធនឹងការរក្សាការសម្ងាត់លើកិច្ចស៊ើបសួរ ពោលគឺបានដាក់កំហិតលើព័ត៌មានណាខ្លះដែលសហចៅក្រមស៊ើបអង្កេតអាចលាតត្រដាងជាសាធារណៈបាន បទប្បញ្ញត្តិទាំងនេះត្រូវយកមកពិចារណារួមគ្នា នៅគ្រប់ពេលទាំងអស់ជាមួយនឹងគោលការណ៍ជាមូលដ្ឋានដែលគ្រប់គ្រងលើកិច្ចដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក *នៅក្នុងចំណោមនោះ*រួមមាន "ជនរងគ្រោះត្រូវទទួលបានការជូនព័ត៌មាន ហើយសិទ្ធិរបស់ជនរងគ្រោះ ត្រូវបានការពារ*ក្នុងអំឡុងពេល*នៃដំណើរការនីតិវិធីរឿងក្តី"[១៨]។ គេកំណត់ថា ការធានាជាមូលដ្ឋាន ដែលបានផ្តល់ជូនដល់ជនរងគ្រោះ ពុំបានផ្តល់លទ្ធភាពសម្រាប់ការបកស្រាយឡើយ ហើយព័ត៌មានដែលមានលក្ខណៈសមស្រប និងទទួលបានទាន់ពេលវេលា ត្រូវផ្តល់ជូនដល់ជនរងគ្រោះ នៅគ្រប់ដំណាក់កាលមុនអង្គសេចក្តី[១៩]។ នៅក្នុងដំណាក់កាលនៃកិច្ចស៊ើបសួរ កាតព្វកិច្ចនេះត្រូវធ្លាក់ទៅលើសហចៅក្រមស៊ើបអង្កេតដោយផ្ទាល់តែម្តង[២០] ដោយហេតុថា អនុលោមតាមវិធានផ្ទៃក្នុង សហចៅក្រមស៊ើបអង្កេតជាអ្នកទទួលខុស

[១៧] វិធាន ៤៩ (២) អនុញ្ញាតឱ្យអ្នកដាក់ពាក្យបណ្តឹងផ្តល់ព័ត៌មានឱ្យសហព្រះរាជអាជ្ញា។

[១៨] វិធាន ២១(១)(គ) នៃវិធានផ្ទៃក្នុង (គូសបញ្ជាក់បន្ថែម)។ សាលដីកាលើករណីដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌរួម ៥២។

[១៩] សាលដីកាលើករណីដើមបណ្តឹងរដ្ឋប្បវេណី ក្នុងសំណុំរឿង ០០២ កថាខណ្ឌរួម ៥២-៥៣។

[២០] សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតលើសេចក្តីប្រកាសព័ត៌មានជាសាធារណៈរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទាក់ទងនឹងសំណុំរឿង ០០៣ ("សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចកោសលុប") ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១១ ឯកសារលេខ D14/1/3 កថាខណ្ឌ ៣១។

ត្រូវលើការបំពេញកិច្ចស៊ើបសួរ ដូច្នេះ សហចៅក្រមស៊ើបអង្កេតមានព័ត៌មានគ្រប់គ្រាន់លើវិសាលភាព និងអង្គហេតុជាក់លាក់នៅក្នុងកិច្ចស៊ើបសួរ។

១១. យើងពិចារណាឃើញថា សហចៅក្រមស៊ើបអង្កេតមានកាតព្វកិច្ចសម្រេចលើខ្លឹមសារនៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅពេលខ្លួនទទួលបានពាក្យសុំទាំងនេះ។ សហចៅក្រមស៊ើបអង្កេតហាក់ដូចជាយល់ឃើញដូចគ្នា នៅពេលគាត់ពិនិត្យនិងសម្រេចលើអង្គសេចក្តីនៃពាក្យសុំរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍។ អាស្រ័យហេតុនេះ នៅពេលដែលពុំទាន់មានព័ត៌មានចាំបាច់សម្រាប់យកមកវាយតម្លៃលើខ្លឹមសារនៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងរឿងក្តីនៅចំពោះមុខ អ.វ.ត.ក សហចៅក្រមស៊ើបអង្កេត ឬអង្គបុរេជំនុំជម្រះ គួរច្រានចោលសេចក្តីសម្រេចរបស់ខ្លួនលើបញ្ហានេះ ដោយរង់ចាំរហូតដល់ពេលមានព័ត៌មានទាំងនោះ នៅក្នុងអំឡុងពេលស៊ើបសួរជាមុនសិន ដែលជាលក្ខខណ្ឌមានចែងក្នុងវិធានផ្ទៃក្នុង។ ការធ្វើចំណាត់ការណាមួយផ្សេងពីនេះ នឹងនាំឱ្យមានការបដិសេធលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ជាការធ្វើឡើងមុនដំណាក់កាលនៃនីតិវិធី ហើយបានធ្វើឱ្យប៉ះពាល់ដល់ប្រព័ន្ធទទួលស្គាល់ដើមបណ្តឹងរដ្ឋប្បវេណីទាំងមូលតែម្តង ដែលប្រព័ន្ធនេះបានបង្កើតឡើងសម្រាប់ជនរងគ្រោះ ស្របតាមវិធានផ្ទៃក្នុងនៃអ.វ.ត.ក។

១២. លើសពីនេះ ដូចអ្វីដែលម្ចាស់បណ្តឹងបានលើកឡើង[២១] យើងកត់សម្គាល់ថា ផ្ទុយពីការអនុវត្តនៅក្នុងសំណុំរឿង ០០១ និងសំណុំរឿង ០០២ មេធាវីតំណាងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០៣ ពុំបានទទួលសិទ្ធិពិនិត្យសំណុំរឿងឡើយ ទោះបីជាក្រោយពីបានដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងលិខិតតំណាងដោយអាណត្តិហើយក្តី។ តាមការយល់ឃើញរបស់យើង វិធាន ២៣ ស្ទួន (២) នៃវិធានផ្ទៃក្នុង នៅពេលពិចារណារួមជាមួយនឹងវិធាន ៥៥ (៦) និង (១១) នៃវិធានផ្ទៃក្នុង បានផ្តល់លទ្ធភាពឱ្យអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិពិនិត្យសំណុំរឿង តាមរយៈមេធាវីតំណាងរបស់ខ្លួន គិតចាប់ពីពេលដាក់ពាក្យសុំរហូតដល់ពេលសេចក្តីសម្រេចបដិសេធចោលពាក្យសុំនេះចូលជាស្ថាពរ។

១៣. យើងយល់ឃើញថា សហចៅក្រមស៊ើបអង្កេតខកខានមិនបានបំពេញលក្ខខណ្ឌនៃគោលការណ៍នៃការបំពេញការងារដោយយកចិត្តទុកដាក់ ដោយមិនបានជូនដំណឹងជនរងគ្រោះឱ្យបានទាន់ពេល

[២១] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៦។

និងគ្រប់គ្រាន់អំពីវិសាលភាពនៃកិច្ចស៊ើបសួរ។ លើសពីនេះ សហចៅក្រមស៊ើបអង្កេតក៏មានការរំលោភច្បាប់ ដោយបានដកហូតពីមេធាវីរបស់ជនរងគ្រោះនូវសិទ្ធិពិនិត្យសំណុំរឿង ០០៣ មុនពេលធ្វើការសម្រេចលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលការធ្វើដូច្នេះគឺបដិសេធមិនផ្តល់ឱកាសដល់ម្ចាស់បណ្តឹងឧទ្ធរណ៍ ក្នុងការធ្វើការសម្រេចចិត្តដោយមានព័ត៌មានគ្រប់គ្រាន់ក្នុងការកែប្រែពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០៣ របស់ខ្លួន ឬបោះបង់បណ្តឹងឧទ្ធរណ៍របស់គាត់ ប្រសិនបើគាត់គិតថា គាត់ពុំមានហេតុផលគួរឱ្យជឿជាក់ថា ព្យសនកម្មដែលគាត់អះអាង មានទំនាក់ទំនងហេតុផលទៅនឹងឧក្រិដ្ឋកម្មទាំងឡាយ ដែលជាលក្ខខណ្ឌតម្រូវ។

១៤. លើសពីនេះ ដោយពិចារណាឃើញថា ម្ចាស់បណ្តឹងឧទ្ធរណ៍មិនត្រូវបានជូនដំណឹងអំពីកិច្ចស៊ើបសួរ ដើម្បីដាក់ និងគាំទ្រពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០៣ របស់ខ្លួនឱ្យបានគ្រប់គ្រាន់នោះ យើងយល់ឃើញថា វាពុំអាចឱ្យយើងពិនិត្យការរំលោភច្បាប់ទៀត ដែលត្រូវបានចោទប្រកាន់នៅក្នុងមូលដ្ឋានទី៣ និងទី៤ នៃបណ្តឹងឧទ្ធរណ៍ឡើយ។ ការរំលោភច្បាប់របស់សហចៅក្រមស៊ើបអង្កេត និងការរំលោភបំពានលើឆន្ទានុសិទ្ធិលើការលាតត្រដាងព័ត៌មាន និងសិទ្ធិពិនិត្យសំណុំរឿង បានធ្វើឱ្យការសម្រេចទាំងមូលលើពាក្យសុំរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ មានភាពអយុត្តិធម៌។ ហេតុដូច្នេះ យើងពិចារណាឃើញថា ដីកាសម្រេចដែលត្រូវបានជំទាស់នេះត្រូវចាត់ទុកជាមោឃៈ ហើយបញ្ហានេះគួរបង្វិលទៅឱ្យសហចៅក្រមស៊ើបអង្កេតវិញ ដើម្បីឱ្យសហចៅក្រមស៊ើបអង្កេត៖ ទី១ អនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនឱ្យស្របទៅតាមច្បាប់ដូចមានចែងនៅក្នុងវិធាន ២១(១)(គ) នៃវិធានផ្ទៃក្នុង ស្តីពីការលាតត្រដាងព័ត៌មានអំពីវិសាលភាពនៃកិច្ចស៊ើបសួរលើសំណុំរឿង ០០៣។ ទី២ ផ្តល់សិទ្ធិពិនិត្យសំណុំរឿង ០០៣ ដូចមានចែងនៅក្នុងវិធាន ២៣*ស្ទួន* (២) វិធាន ៥៥(៦) និង (១១) នៃវិធានផ្ទៃក្នុង ដល់មេធាវី តំណាងរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍។ ទី៣ អនុញ្ញាតឱ្យម្ចាស់បណ្តឹងឧទ្ធរណ៍កែប្រែពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០៣ ក្នុងរយៈពេល ១០ ថ្ងៃ គិតចាប់ពីថ្ងៃដែលមេធាវីរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ទទួលបានសិទ្ធិពិនិត្យសំណុំរឿង។ ទី៤ ពិនិត្យឡើងវិញ និងឱ្យស្របទៅតាមច្បាប់លើពាក្យសុំដែលម្ចាស់បណ្តឹងឧទ្ធរណ៍បានដាក់សារជាថ្មី។ ទោះបីជាដីកាសម្រេចដែលត្រូវបានជំទាស់នៅមានសុពលភាព ដោយហេតុថា អង្គបុរេជំនុំជម្រះពុំអាចធ្វើសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍នេះក៏ដោយ ក៏យើងកត់សម្គាល់ឃើញថា សហចៅក្រមស៊ើបអង្កេតនៅតែមានឱកាសប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ខ្លួន

ក្នុងនាមជាចៅក្រមដើម្បីពិចារណាឡើងវិញលើដីកាសម្រេចនេះ[២២] ដោយអាចយកសេចក្តីពិចារណារបស់យើងនៅក្នុងមតិយោបល់នេះ និងសេចក្តីពិចារណាដែលពាក់ព័ន្ធផ្សេងទៀត មកពិចារណាឡើងវិញបានក្នុងករណីចាំបាច់។

**នៅភ្នំពេញ ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០១២**

**Rowan DOWNING** **Katinka LAHUIS**

---

[២២] យើងយោងលើឯកសារមូលដ្ឋានផ្លូវច្បាប់ ដែលបានយកមកធ្វើជាសំអាងនៅក្នុងមតិយោបល់របស់យើង ទាក់ទងនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ស្តីពីការដាក់សារឡើងវិញនូវសំណើសុំបំពេញកិច្ចស៊ើបសួរចំនួន ៣ ចុះថ្ងៃទី ១៥ វិច្ឆិកា ២០១១ ឯកសារលេខ D26/1/3 កថាខណ្ឌ ២០ កំណត់សំគាល់លេស ៣៥។